សលាកប័ត្រព័ត៌មាន៖ កម្រងអត្ថបទសេរីភាពមូលដ្ឋាន: ការគាបសង្កត់លើប្រព័ន្ធអ៊ិនធើណេត

សិទ្ធិមូលដ្ឋាន៖ សេរីភាពបញ្ចេញមតិ

សេចក្តីព្រួយបារម្ភរបស់ម.ស.ម.ក៖ សកម្មភាពថ្មីៗនៃការបិទគេហទំព័រមួយចំនួន ឆ្លុះបញ្ចាំងពីអសមត្ថភាពរបស់រាជរដ្ឋាភិបាលកម្ពុជា (រដ្ឋាភិបាល) ក្នុងការទទួលយកពាក្យរិះគន់ សូម្បីតែជាពាក្យរិះគន់ក្នុងន័យស្ថាបនា និងបានបង្ហាញឲ្យឃើញរួចជាស្រេចក្នុងការបង្កើនកម្រិតការគាបសង្កត់របស់រដ្ឋាភិបាលលើប្រព័ន្ធអ៊ិនធើណេត។ កិច្ចប្រឹងប្រែងក្នុងការគាបសង្កត់ដូចដែលបានគេរាយការណ៍នេះ បានបញ្ជាក់ពីគោលជំហររបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការចង់គ្រប់គ្រងលើប្រព័ន្ធផ្សព្វផ្សាយបែបថ្មី ឲ្យដូចនឹងការគ្រប់គ្រងដែលកំពុងតែមានចំពោះប្រព័ន្ធផ្សព្វផ្សាយបែបបច្ចុប្បន្នដូច្នោះដែរ។

សេចក្តីផ្តើម

សលាកប័ត្រព័ត៌មាននេះ នឹងផ្តល់នូវរូបភាពទូទៅអំពីអត្រាការប្រើប្រាស់អ៊ិនធើណេតក្នុងព្រះរាជណាចក្រកម្ពុជា (កម្ពុជា) ការវិវត្តន៍នាពេលបច្ចុប្បន្នដែលឆ្ពោះទៅរកការគាបសង្កត់លើប្រព័ន្ធអ៊ិនធើណេត និងអំពីការជះឥទ្ធិពលយ៉ាងធ្ងន់ធ្ងរចំពោះសេរីភាពបញ្ចេញមតិនៅកម្ពុជា។ សលាកប័ត្រមួយនេះត្រូវបានសរសេរឡើងដោយ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ដែលជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និង ការពារលទ្ធិប្រជាធិបតេយ្យ និង គោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិប្រជាពលរដ្ឋ និងសិទ្ធិនយោបាយ នៅកម្ពុជា។

អត្រាការប្រើប្រាស់អ៊ិនធើណេត

យោងតាមធនាគារពិភពលោក អត្រាការប្រើប្រាស់អ៊ីនធើណេតនៅកម្ពុជាកើនឡើងដល់ទៅ ១០ដង ចាប់ពី ០.០៥% ក្នុងឆ្នាំ ២០០០ ទៅ ០.៥% ក្នុងឆ្នាំ២០១០ បង្ហាញឲ្យឃើញពីសារសំខាន់របស់អ៊ិនធើណេតដែលកើនឡើង ហើយបណ្តាលឲ្យរដ្ឋាភិបាលមានការព្រួយបារម្ភ ។ ទោះជាយ៉ាងណាក៏ដោយ ប្រជាពលរដ្ឋភាគច្រើន ជាពិសេសអ្នកដែលរស់នៅតាមតំបន់ជនបទ នៅមិនទាន់មានលទ្ធភាពប្រើប្រាស់អ៊ិនធើណេតនៅឡើយទេ ។ រដ្ឋាភិបាលកម្ពុជាត្រូវតែប្រឹងប្រែងឲ្យអស់ពីសមត្ថភាពក្នុងការអភិវឌ្ឍយន្តការដើម្បីបង្កើនការប្រើប្រាស់អ៊ិនធើណេតនៅកម្ពុជា ព្រោះមនុស្សគ្រប់គ្នាគួរតែមានសិទ្ធិប្រើប្រាស់អ៊ិនធើណេត ។

ការគាបសង្កត់លើប្រព័ន្ធអ៊ិនធើណេត

រដ្ឋាភិបាលបានបង្ហែរចំណាប់អារម្មណ៍លើអ៊ិនធើណេត ហើយទង្វើរនេះហាក់ដូចជាការធ្វើសមរភូមិប្រយុទ្ធជាមួយនឹងសេរីភាពបញ្ចេញមតិនៅកម្ពុជា ។ ថ្មីៗនេះ មានការបិទគេហទំព័រមួយចំនួនដែលត្រូវបានរាយការណ៍ដូចខាងក្រោម ៖

- នៅចុងខែ មករា ឆ្នាំ២០០៩ គេហទំព័ររបស់សិល្បករ "ជនជាតិខ្មែរអាមេរិកាំង" ឈ្មោះកុក ឡ ត្រូវបានបិទ បន្ទាប់ពីស្នាដៃរបស់គាត់បង្កើតឲ្យមានភាពចម្រូងចម្រាស់ ដោយបានគូររូបអប្សរា (រូបតំណាងស្ត្រីខ្មែរក្នុងរឿងនិទានបុរាណ) អាក្រាតដែលបានធ្វើឲ្យរដ្ឋមន្ត្រីក្រសួងកិច្ចការនារីខឹងសម្បារ។
- កាលពីថ្ងៃទី ០៨ ខែកុម្ភៈ ឆ្នាំ២០០៩ គេហទំព័រ ក្លូបិលវីតនេស អ្នកឃ្លាំមើលអំពើពុករលួយដែលមានទីតាំងនៅក្នុងប្រទេសអង់គ្លេសត្រូវបានបិទ ដោយមិនអាចចូលទស្សនាបានតាមរយៈ សេវាកម្មអ៊ិនធើណេត អង្គរណេត ក្រោយពីស្ថាប័ននេះបានចេញរបាយការណ៍ដែលមានចំណងជើងថា "ប្រទេសសម្រាប់លក់" ទាក់ទងនឹងធនធានប្រេងដែលទើបតែរកឃើញ និងឧស្សាហកម្មរ៉ែនៅកម្ពុជា។ មន្ត្រីរដ្ឋាភិបាលបដិសេធទទួលដឹងពីការបិទគេហទំព័រមួយនេះទេ។

- កាលពីថ្ងៃទី ១៩ ខែមករា ឆ្នាំ២០១១ គេហទំព័រ ប្លក់ស្ពត នៅកម្ពុជាត្រូវបានបិទបន្ទាប់ពីមានការបញ្ជាពីក្រសួងព័ត៌មានទៅគ្រប់ក្រុមហ៊ុនដែលផ្តល់សេវាកម្មអ៊ិនធើណេត។ អ្នកប្រើប្រាស់សេវាកម្មរបស់ អ៊ីស៊ីខម ដែលជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុនផ្តល់សេវាកម្មអ៊ិនធើណែតដែលកំពុងតែកើនឡើង បានរអ៊ូថាពួកគាត់មិនអាចបើកមើលគេហទំព័រមួយចំនួនបានរួមទាំង ខេអាយ មីខៀ ដែលជាគេហទំព័រសរសេរអត្ថបទរិះគន់ចំពោះរដ្ឋាភិបាល ទោះបីជាក្រោយមកអ្នកគ្រប់គ្រងក្នុងក្រុមហ៊ុន អ៊ីស៊ីខម បានបដិសេធតាមរយៈការសរសេរថាមិនបានទទួលបញ្ជាណាមួយពីរដ្ឋាភិបាលនោះទេ ។ រដ្ឋមន្ត្រីក្រសួងព័ត៌មាន លោកខៀវ កាញ៉ារិទ្ធ ក៏បានបដិសេធផងដែរថាលោកមិនបានពាក់ព័ន្ធក្នុងរឿងនេះទេ ។ ក្រោយមកមិនយូរប៉ុន្មាន គេហទំព័រទាំងនោះក៏អាចត្រូវបានចូលទស្សនាបានជាធម្មតាវិញ លើកលែងតែអតិថិជនរបស់ក្រុមហ៊ុនមិតហ្វូន។
- ដើមខែកុម្ភៈ ឆ្នាំ ២០១១ ប្រទេសកម្ពុជារងគ្រោះនូវរលកថ្មីនៃការបិទគេហទំព័រ ជាថ្មីម្តងទៀតដែលមានគេហទំព័រ ខេអាយ មីខៀ រួមបញ្ចូលទាំង ខ្មែររូបនីយកម្ម ដែលជាគេហទំព័ររបស់អ្នកសារពត៌មានពលរដ្ឋដែលភាគច្រើនសរសេររិះគន់រដ្ឋាភិបាល និងគេហទំព័ររបស់អ្នកគូររូបតូកបែបនយោបាយជនជាតិខ្មែរ សក្រាំ ផងដែរ ។ សារព័ត៌មានភ្នំពេញប៉ុស្តិ៍រាយការណ៍ថា នៅពេលដែលអតិថិជន វ៉ាយខេម (ក្រុមហ៊ុនមួយដែលរងឥទ្ធិពល) ព្យាយាមបើកមើលគេហទំព័រ ខេអាយ មីខៀ ពួកគេនឹងឃើញសារមួយសរសេរថាគេហទំព័រមួយនេះត្រូវបាន "បិទដោយសារតែបញ្ជាមកពីក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍កម្ពុជា"។ បុគ្គលិករបស់ វ៉ាយខេម ម្នាក់ដែលសុំមិនបញ្ចេញឈ្មោះ បានប្រាប់សារព័ត៌មានថា ក្រសួងបានបញ្ជាឲ្យបិទគេហទំព័ររបស់ ខេអាយ មីខៀ ព្រោះតែគេហទំព័រនេះបាន "ប៉ះពាល់ដល់រដ្ឋាភិបាល" ។
- នៅថ្ងៃទី ១៦ ខែកុម្ភៈ ឆ្នាំ ២០១១ សារព័ត៌មានភ្នំពេញប៉ុស្តិ៍ បានបង្ហាញពីអ៊ីម៉ែលដែលបានលេចធ្លាយមកពីមន្ត្រីជាន់ខ្ពស់នៅក្នុងក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍។ ក្នុងអ៊ីម៉ែលនោះ បានសរសេរអបអរសាទរដល់ក្រុមហ៊ុនផ្តល់សេវាកម្មអ៊ិនធើណែតចំនួន ១០ ដែលមានរួមទាំង អ៊ីស៊ីខម ដែលបានបិទគេហទំព័រមួយចំនួន រួមមានប្លក់ស្ពត ខេអាយ មីខៀ ខ្មែររូបនីយកម្ម និង សាក្រាំ ដែលគេហទំព័រទាំងអស់នេះល្បីពីការផ្សព្វផ្សាយព័ត៌មាន រិះគន់រដ្ឋាភិបាល។

ជាងនេះទៅទៀត ក្នុងខែតុលា ឆ្នាំ ២០០៩ ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ មានផែនការបង្កើតឲ្យមានប្រព័ន្ធចែកចាយអ៊ិនធើណែតដែលរដ្ឋជាអ្នកគ្រប់គ្រង និងតាមដានពីចរាចរណ៍អ៊ិនធើណែតទាំងអស់ ហើយការណ៍នេះធ្វើឲ្យរដ្ឋាភិបាលអាចបិទគេហទំព័រណាមួយក៏បានដោយសេរី ប្រសិនណាបើរដ្ឋាភិបាលយល់ថាគេហទំព័រនោះ "មិនសមរម្យ" ប៉ុន្តែផែនការនេះត្រូវបានលុបចោល ព្រោះតែគ្មានការគាំទ្រពីផ្នែកព័ត៌មានវិទ្យា និងអ្នកជំនួញ។ ទោះជាយ៉ាងណាក៏ដោយ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍បានបង្ហាញតម្រុយថានាពេលអនាគតខាងមុខនេះ នឹងតម្រូវឲ្យសុំអាជ្ញាប័ណ្ណ ។ មិនតែប៉ុណ្ណោះ ថែមទាំងមានលេចពាក្យចចាមអារ៉ាមថា រដ្ឋាភិបាលក៏កំពុងតែពិចារណានូវច្បាប់ថ្មីមួយដើម្បីគ្រប់គ្រងការប្រើប្រាស់អ៊ិនធើណែត ដោយសារថានេះ គឺជាទម្រង់សារព័ត៌មានតែមួយគត់ដែលមិនត្រូវបានគ្រប់គ្រងសោះ។

សេរីភាពបញ្ចេញមតិ

ស្ថានភាពសេរីភាពបញ្ចេញមតិនៅកម្ពុជាគឺមានលក្ខណៈចុះខ្សោយ ទោះបីត្រូវបានធានាដោយទាំងច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដូចមានចែងក្នុងច្បាប់រដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា និងមានការផ្តល់សច្ចាប័នចំពោះអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង សិទ្ធិនយោបាយក៏ដោយ ។ យោងតាមរបាយការណ៍សេរីភាពសារពត៌មានថ្មីៗ របស់អ្នកសារពត៌មានគ្មានព្រំដែន បានចាត់ចំណាត់ថ្នាក់ឲ្យកម្ពុជានៅលេខរៀងទី ១២៨ ក្នុងចំណោម ១៧៨ប្រទេស។ រដ្ឋាភិបាលនៅតែរក្សាការត្តោបត្តាប់ លើបណ្តាញទូរទស្សន៍ វិទ្យុ និងកាសែត ។ ច្បាប់ព្រហ្មទណ្ឌថ្មីមាន ៩ប្បញ្ញត្តិ ដែលចាត់ទុកទម្រង់នៃការបញ្ចេញមតិជាច្រើនចូលជាទោសឧក្រិដ្ឋ ស្របពេលដែលពង្រាង

ច្បាប់គ្រប់គ្រង (១)សហជីព និង(២) សមាគម និងអង្គការមិនមែនរដ្ឋាភិបាល បានគម្រាមដល់សិទ្ធិសេរីភាពបញ្ចេញមតិកាន់តែខ្លាំងឡើង ។

សេចក្តីសន្និដ្ឋាន

សេរីភាពក្នុងការប្រើប្រាស់អ៊ិនធើណេតនឹងត្រូវកាត់បន្ថយកម្រិតណានោះ នៅមិនទាន់ដឹងច្បាស់នៅឡើយទេ ។ ខណៈពេលដែលសេរីភាពពាក់ព័ន្ធនឹងប្រព័ន្ធផ្សព្វផ្សាយបែបថ្មីមានលក្ខណៈប្រសើរ ដែលនេះអាចបណ្តាលមកពីរដ្ឋាភិបាលកម្ពុជាប្រហែលជាមានបញ្ហាប្រឈមជាមួយនឹងបច្ចេកវិទ្យាក្នុងការគាបសង្កត់លើប្រព័ន្ធអ៊ិនធើណេត ការបិទគេហទំព័រមួយចំនួនក្នុងពេលថ្មីៗនេះ បានបង្កើនការព្រួយបារម្ភថា ការគាបសង្កត់លើប្រព័ន្ធអ៊ិនធើណេតនឹងក្លាយទៅជាការពិតនៅកម្ពុជាក្នុងពេលឆាប់ៗនេះ ។ ព្រឹត្តិការណ៍ថ្មីៗទូទាំងសកលលោកបានបង្ហាញឲ្យឃើញថា ប្រព័ន្ធផ្សព្វផ្សាយបែបថ្មីជាកម្លាំងដ៏មានប្រសិទ្ធិភាពក្នុងការបង្កើតឲ្យមានការផ្លាស់ប្តូរជាវិជ្ជមាន ក្នុងនោះមានឧទាហរណ៍ជាច្រើនដែលបង្ហាញពីការងើបឡើងដ៏គួរឲ្យកត់សម្គាល់ក្នុងការប្រឈមមុខជាមួយនឹងការគាបសង្កត់របស់រដ្ឋាភិបាល ហើយរដ្ឋាភិបាលពិតជាបានកត់សម្គាល់ត្រង់ចំណុចនេះជាមិនខាន ។ ក្នុងពេលដែលកម្ពុជាកំពុងឈរលើផ្លូវបំបែក ដោយមិនច្បាស់ថារដ្ឋាភិបាលនឹងតបតដោយវិធីណាចំពោះការបញ្ចេញមតិយោបល់តាមរយៈប្រព័ន្ធផ្សព្វផ្សាយបែបថ្មី ជាចាំបាច់ណាស់ដែលរដ្ឋាភិបាលគួរទទួលស្គាល់ថា មានតែការចូលរួមក្នុងការសន្ទនាតាមបណ្តាញអ៊ិនធើណេត និង តាមរយៈការឆ្លើយតបទៅនឹងការរិះគន់ដោយផ្តល់នូវអំណះអំណាងដ៏សមហេតុផលនោះទេ ដែលអាចជួយកាត់បន្ថយនូវការរិះគន់ដែលរដ្ឋាភិបាលមានបំណងចង់បង្ក្រាបនោះ។

ម.ស.ម.ក អំពាវនាវឲ្យរដ្ឋាភិបាលដាក់ចេញយន្តការនានា ដើម្បីបង្កើនការប្រើប្រាស់អ៊ិនធើណេតនៅកម្ពុជា ប្រឆាំងនឹងគោលនយោបាយបង្ក្រាបដែលកំពុងតែរៀបចំអនុវត្ត និង ដើម្បីលើកស្ទួយលំហរប្រព័ន្ធអ៊ិនធើណេតសម្រាប់សេរីភាពបញ្ចេញមតិ ដោយធានាថាឧបសគ្គចាស់ៗនឹងមិនត្រូវបានយកមកអនុវត្តក្នុងឱកាសថ្មីនេះ។ ម.ស.ម.ក គាំទ្រឲ្យក្រុមអ្នកប្រើប្រាស់អ៊ិនធើណេត និង អ្នកពាក់ព័ន្ធក្នុងប្រព័ន្ធផ្សព្វផ្សាយបែបថ្មី បន្តការប្រើប្រាស់ និង បង្កើតនូវលំហថ្មីសម្រាប់ប្រព័ន្ធផ្សព្វផ្សាយ ដើម្បីអនុញ្ញាតឲ្យមានការពិភាក្សា និង ការជជែកវែកញែក ថែមទាំងសង្ឃឹមថារដ្ឋាភិបាលនឹងបន្តគាំទ្រប្រព័ន្ធផ្សព្វផ្សាយបែបថ្មីតាមរយៈការចូលរួមការសន្ទនាតាមប្រព័ន្ធអ៊ិនធើណេត ។

ព័ត៌មានបន្ថែម សូមទាក់ទង

លោក អ៊ូ វីរៈ តាមរយៈទូរស័ព្ទលេខ +៨៥៥ (0)១២ ៤0 ៤0 ៥១ ឬតាមរយៈអ៊ីម៉ែល ouvirak@cchrcambodia.org **ឬលោករ៉ូប៊ឺត ហ្វីនច៍ +៨៥៥(0)៧៨ ៨0 ៩៩ ៦0 ឬអ៊ីម៉ែល** robert.finch@cchrcambodia.org